# លោកយាយ
# ហ្វ្រនន



WRITTEN BY KAREN SHELTON FICHEROUX        ILLUSTRATED BY ERICA ARTHUR

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



រឿង លោកយាយហ្វ្រេននីមិនត្រឹមតែជាសៀវភៅរឿងសាមញ្ញសម្រាប់កុមារនោះទេ ប៉ុន្តែវាជារឿងភាវពិតមួយ ក៏ជាមេរៀនដ៏មានតម្លៃដែលបានឆ្លុះបញ្ចាំងពីសប្បុរសធម៌។ ការរួមចំណែកជាមួយគ្នាអាចផ្លាស់ប្តូរពិភពលោកដ៏ធំធេងមួយនេះ។ មនុស្សគ្រប់រូបអាចស្វែងរកតាមវិធីផ្សេងៗគ្នា ដើម្បីជួយអ្នកដទៃនិងធ្វើឱ្យពិភពលោកទាំងមូលក្លាយជាទីសប្បុរស។



លោកយាយហ្វ្រេននីចូលចិត្តចាក់អំបោះណាស់។
សំឡេងម្ជុលចាក់គឺជាសេចក្ដីសុខរបស់លោកយាយ។



ខ្លីកខ្លាក់! ខ្លីកខ្លាក់! ពេលគាត់មើលទូរទស្សន៍!
ខ្លីកខ្លាក់! ខ្លីកខ្លាក់! ពេលគាត់និយាយជាមួយមិត្តភក្តិ!
ខ្លីកខ្លាក់! ខ្លីកខ្លាក់! ពេលគាត់ធ្វើដំណើរកម្សាន្ត!
ខ្លីកខ្លាក់! ខ្លីកខ្លាក់! ពេលគាត់អង្គុយរង់ចាំ!
ខ្លីកខ្លាក់! ខ្លីកខ្លាក់! គាត់ចាក់អំបោះដោយមិនចាំបាច់មើលម្ជុល!



គាត់បានចាក់អំបោះធ្វើជាមួក កន្សែង អាវនិងភួយ ដើម្បីទុកប្រើប្រាស់ក្នុងគ្រួសារដ៏កក់ក្តៅរបស់គាត់។



លោកយាយហ្វ្រេននីបានសម្រេចចិត្តថាគួរដល់ពេលចាប់ផ្តើមជួយអ្នកដទៃហើយ។
អ្នកក្រីក្រ អ្នកគ្មានផ្ទះសំបែង អ្នករស់នៅតែម្នាក់ឯង អ្នកដែលរងា
និងអ្នកត្រូវការភាពកក់ក្ដៅ។



គាត់បានចាក់ហើយចាក់ទៀត ទាំងថ្ងៃទាំងយប់។ ខ្លីកខ្លាក់! ខ្លីកខ្លាក់!
រហូតបន្ទប់របស់គាត់ពោរពេញទៅដោយម្លូកនិងកន្សែងក្លួឱ្យស្រលាញ់ដែលបានផ្តល់នូវភាពកក់ក្តៅ។
មានទាំងម្លូកនិងកន្សែងធំ តូច ល្មម សម្រាប់ទារកតូចៗគ្របដណ្តប់ដោយពណ៌ឥន្ទធនូ។



លោកយាយហ្វ្រេននីបន្តការចាក់ ហើយចាក់ទៀត ទាំងថ្ងៃទាំងយប់។ ខ្ចីកខ្ចាក់! ខ្ចីកខ្ចាក់!
រហូតបន្ទប់របស់គាត់ពោរពេញទៅដោយតុក្កតាគួរឱ្យស្រលាញ់។
មានទាំងតុក្កតា ធំ តូច ល្មម សម្រាប់ទារកតូចៗគ្របដណ្តប់ដោយពណ៌ឥន្ទធនូ។



លោកយាយហ្វ្រេននីបានរៀបចំរបស់ទាំងនោះដាក់ចូលក្នុងវ៉ាលីដ៏ធំមួយដែលពោរពេញទៅដោយមួក កន្សែងនិងតុក្កតា
យ៉ាងណែនតាន់តាប់ស្ទើរតែផ្ទុះវ៉ាលីទៅហើយ។ គាត់បានផ្ញើរបស់ទាំងនោះទៅដល់អ្នកដែលត្រូវការពិតប្រាកដទីទាល់នៅតំបន់
ដាច់ស្រយាល។



មនុស្សជាច្រើនបានទទួលអារម្មណ៍កក់ក្តៅនៅពេលប្រើ ហើយបានរក្សាកន្សែងនិងតុក្កតាដ៏ស្រស់ស្អាតរបស់លោកយាយហ្វ្រេននី
ទាំងក្តីនឹករលឹក។ អ្នកទាំងនោះមិនធ្លាប់បានជួបលោកយាយហ្វ្រេននី ដូច្នេះហើយ
មិនអាចនិយាយពាក្យអរគុណទៅកាន់គាត់ផ្ទាល់ទេ។



លោកយាយហ្វ្រេននីដឹងថា ការជួយមនុស្សធ្វើឱ្យមានក្ដីសុខ ទើបគាត់បន្តចាក់អំបោះទៀត។
មិត្តភក្ដិរបស់លោកយាយចង់ទទួលបានអារម្មណ៍រីករាយនិងការជួយមនុស្សដែរ ដូច្នេះពួកគាត់ចាប់ផ្ដើមចាក់អំបោះជាមួយគ្នា។
ម្ជុលចាក់អំបោះជាច្រើនត្រូវបានធ្វើការយ៉ាងសកម្ម។ ខ្លីកខ្លាក់! ខ្លីកខ្លាក់! យើងរួមគ្នាដើម្បីជួយមនុស្សនៅក្នុងពិភពលោក។
អំឡុងពេលមិនយូរប៉ុន្មាន របស់ទាំងនោះត្រូវបានដាក់ចូលក្នុងវ៉ាលីរចាល់សម្រាប់ផ្ញើ។ អំបោះចាក់ចម្រុះពណ៌ជាច្រើនត្រូវបាន
ជួយដល់មនុស្សក្នុងលោកឱ្យមានភាពកក់ក្ដៅនិងរីករាយ។



លោកយាយហ្វ្រេននីបានចាក់ភួយជាច្រើន។ មានទាំងភួយធំ ហើយទន់កក់ក្តៅគួរឱ្យចង់ដណ្តប់។
ភួយនីមួយៗសុទ្ធតែចាក់ដោយដៃជាច្រើន។ ខ្ញីកខ្លាក់! ខ្ញីកខ្លាក់!
ខ្លះមាននាងឆ្នូត ខ្លះមាននាងជាការ៉ូ។ ឯខ្លះទន់ដូចសំឡី ខ្លះមានសភាពទន់ទ្វេដងនិងខ្លះទៀតទន់ដូចរោមសត្វ។
គ្រប់ភួយទាំងអស់សុទ្ធតែជាពណ៌ចម្រុះស្រស់ឆើតឆាយនិងមើលទៅកក់ក្តៅយ៉ាងខ្លាំង។



លោកយាយហ្វ្រេននីបានផ្តល់ភួយជាអំណោយជូនដល់អ្នកជំងឺនៅឯមន្ទីរពេទ្យ។
អ្នកដែលមានកូនតូច ចាស់ជរានិងអ្នកដែលត្រូវការក្តីស្រឡាញ់ពិតប្រាកដ។




ទីណាមានភួយទីនោះតែងតែធ្វើឱ្យមនុស្សមានក្ដីស្រឡាញ់និងភាពកក់ក្ដៅ។
ភួយទាំងនោះបានធ្វើឱ្យពួកគេមានអារម្មណ៍សប្បាយរីករាយដូចមានមិត្តម្នាក់នៅក្បែរជានិច្ច។




លោកយាយហ្វ្រេននីស្រឡាញ់ការចាក់អំបោះ។  គាត់គឺជាស្ត្រីសាមញ្ញម្នាក់នៅក្នុងពិភពលោកដ៏ធំធេងមួយនេះ។
យ៉ាងណាមិញ គាត់បានបង្ហាញឱ្យយើងឃើញថា មនុស្សម្នាក់ៗអាចធ្វើឱ្យពិភពលោកមួយនេះមានភាពស្រស់បំព្រងបាន។

សៀវភៅរឿងនេះសូមឧទ្ទិសជូនម៉ាក់របស់ខ្ញុំគឺ Frances Shelton។ ប៉ាម៉ាក់របស់ខ្ញុំបានស្រលាញ់គ្នាតាំងពីអាយុ ១៥ឆ្នាំ ហើយបានរៀបការនៅអាយុ ១៨ឆ្នាំ។ ពួកគាត់គឺជាពិភពលោកទាំងមូលដែលមិនអាចខ្វះគ្នាបាន។ នៅពេលអាយុ ២០ឆ្នាំ ប៉ាម៉ាក់មានខ្ញុំ មិនយូរប៉ុន្មានពួកគាត់ក៏មានប្អូនស្រីរបស់ខ្ញុំតាមក្រោយ។ ទោះបីពួកយើងរស់នៅក្នុងភាពក្រីក្រក្នុងកសិដ្ឋានក៏ដោយ ( ពួកយើងចាំមិនសូវច្បាស់ពីអតីតកាលទាំងអស់នោះទេ )។ ពួកគាត់បានផ្តល់ឱ្យយើងនូវវ័យកុមារភាពដែលពោរពេញដោយក្តីស្រលាញ់។ ការផ្តល់ចៅប្រុសទាំងពីរសម្រាប់ជីដូនជីតាគឺជាក្តីស្រលាញ់ដ៏មានន័យចំពោះពួកគាត់។





ប៉ារបស់ខ្ញុំបានលាចាកលោកនៅអាយុ ៥២ឆ្នាំ ហើយម៉ាក់របស់ខ្ញុំហាក់ដូចជាបាត់បង់ពិភពលោកទាំងមូល។ គាត់បាត់បង់ដៃគូជីវិតដែលជាមិត្តភក្តិជិតស្និទ្ធបំផុត  ហើយគាត់ត្រូវបានចាកចេញពីកសិដ្ឋានក្នុងពេលតែមួយ។ បន្ទាប់មកគាត់បានតស៊ូជាមួយជំងឺបាក់ទឹកចិត្តអស់រយៈពេលជាច្រើនឆ្នាំ ទីបំផុតម៉ាក់បានរកឃើញខ្លួនឯងសារជាថ្មីម្តងទៀតជាមួយនឹងការចាក់អំបោះបង្កើតជារបស់ប្រើប្រាស់ ហើយគាត់បានផ្ញើជាជំនួយជុំវិញពិភពលោក។ ម៉ាក់បានធ្វើដំណើរកំសាន្តទស្សនកិច្ចចំនួន ៣៥ប្រទេស ដែលជាស្នាដៃពីការចាក់អំបោះរបស់គាត់ដល់អ្នកដែលខ្វះខាត និងអ្នកដែលត្រូវការពិតប្រាកដ។
ខ្ញុំពិតជាមានមោទនភាពចំពោះម៉ាក់របស់ខ្ញុំខ្លាំងណាស់។ ការបង្កើតសៀវភៅនេះគឺ ដើម្បីរំលឹកស្នាដៃនិងការព្យាបាលជម្ងឺផ្លូវចិត្តរបស់ខ្ញុំក្នុងការទប់ទល់នៃការបាត់បង់ម៉ាក់។ ខ្ញុំសង្ឃឹមថាសៀវភៅមួយនេះនឹងធ្វើឱ្យអ្នករីករាយ និងរកឃើញខ្លួនឯងសារជាថ្មីដូចម៉ាក់របស់ខ្ញុំដែរ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

TUKTUK

Rotary

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែលមិនរកប្រាក់ចំណេញនិងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍។

អង្គការ(R4C)បានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្របទៅនឹងកម្មវិធីសិក្សារបស់ក្រសួងនិងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រដើម្បីទទួលបានធនធានបង្កើន៖ https://rermork.org/

មូលនិធិផ្តល់ដោយអង្គការTukTukនិងអង្គការសមាគមន៍រ៉ូតារីក្លឹប។

ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកស្ម័គ្រចិត្តនិងបុគ្គលិកទាំងអស់នៅក្នុងអង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C) ដែលបានបង្កើតសៀវភៅនេះឡើងដោយក្តីមេត្តាធម៌។

ទទួលបានព័ត៌មានបន្ថែម

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្កើន